ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៦ សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

### ១- សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាលគឺៈ (១)-**ដំណាក់កាលទី១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ខែឧសភា, (២)-**ដំណាក់កាលទី២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង (៣)-**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ នៅដំណាក់កាលទី១ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ ផ្អែកលើក្របខណ្ឌគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ដើម្បីឱ្យគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ធ្វើការពន្យល់ និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងបង្ហាញអំពីតម្រូវការចំណាយរយៈពេល ៣ ឆ្នាំ សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ដែលនឹងរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**"។ សម្រាប់ដំណាក់កាលទី២ នេះ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០២០ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដូច្នេះ សារាចរណែនាំនេះ នឹងដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ, អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។

ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍

ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយ ទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

២- ក្នុងឆ្នាំ២០១៨ កន្លងមកនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនលើសពីការរំពឹងទុករហូតដល់ ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ សមិទ្ធផលសេដ្ឋកិច្ចដ៏គួរជាទីមោទនៈនេះ អាចសម្រេចទៅបានដោយសារកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រឹមត្រូវ និងសមស្រប។ ជារួម កំណើននេះត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ តាមរយៈការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យដូចជា ការវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស, ការប្រើប្រាស់ក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ, ហើយសបញ្ជាក់យ៉ាងប្រត្យ័កនូវការកើនឡើងនូវទំនុកចិត្តរបស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសចំពោះភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា។

៣- ក៏ប៉ុន្តែ ការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកក្នុងពេលបច្ចុប្បន្ន បានបង្ហាញថាកំណើនសេដ្ឋកិច្ចពិភពលោកកំពុងបន្តថមថយនិងស្ថិតក្នុងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើងៗ។ តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ, សេដ្ឋកិច្ចពិភពលោកនឹងមានកំណើន ៣,៣% នៅឆ្នាំ២០១៩ ដែលទាបជាងឆ្នាំ២០១៨, និង ៣,៦% នៅឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃការថមថយទំនុកចិត្តវិនិយោគ, ការបង្អាក់នៃច្រវ៉ាក់ផលិតកម្មសកល និងការកើនយឺតនៃផលិតភាពផលិតកម្មជារួម ដែលបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្ម និងភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មសកល, និងការបន្តកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចិន។ ការកើនឡើងនូវភាពមិនប្រាកដប្រជា និងបញ្ហាប្រឈមរបស់សេដ្ឋកិច្ចសកលនេះ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែងាយរងគ្រោះ និងអាចជួបហានិភ័យខាងក្រៅមួយ ចំនួនរួមមាន៖ ភាពមិនច្បាស់លាស់នៃការដកការអនុគ្រោះពន្ធលើគ្រប់មុខទំនិញលើកលែងសព្វាវុធ (EBA) ដោយសហភាពអឺរ៉ុប, ការថយចុះជាងការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចចិន, បញ្ច័យអវិជ្ជមាននៃភាពតានតឹងកាន់តែខ្លាំងនៃសង្គ្រាមពាណិជ្ជកម្ម និងសង្គ្រាមបច្ចេកវិទ្យា រវាងសហរដ្ឋអាមេរិកនិងចិន, ភាពមិនប្រាកដប្រជានៃគោលនយោបាយរបស់សហរដ្ឋអាមេរិក ក៏ដូចជា បញ្ហាភូមិសាស្ត្រនយោបាយតំបន់ និងពិភពលោកដែលកាន់តែស្មុគស្មាញ ហើយអាចឈានទៅរក "**សង្គ្រាមត្រជាក់ថ្មី**", បញ្ហាភេរវកម្ម និងសន្តិសុខសកល, ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិ ជាដើម។ ទន្ទឹមនេះ កម្ពុជាក៏អាចជួបបញ្ហាប្រឈម និងហានិភ័យក្នុងស្រុកមួយចំនួន រួមមាន៖ (១)- មូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត និងល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ចមានភាពយឺតយ៉ាវ; (២)-ថ្លៃអគ្គិសនីនៅមានកម្រិតខ្ពស់នៅឡើយបើប្រៀបធៀបជាមួយប្រទេសជិតខាង និងបញ្ហាអស្ថិរភាពនៃការផ្គត់ផ្គង់; (៣)-ភាពនៅទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូននិងប្រព័ន្ធឡូជីស្ទីក; (៤)- កំណើនផលិតភាពពលកម្មទាប និងកង្វះពលកម្មជំនាញ; (៥)- សម្ពាធនៃការកើនឡើងប្រាក់ឈ្នួល; (៦)- នីតិវិធី

ស្មុគស្មាញ និងការបន្តនៅមានសេសសល់នូវកម្រែសេវាក្រៅផ្លូវការមួយចំនួនដែលបង្កជាបញ្ហាដល់ការធ្វើធុរកិច្ច; និង (៧)- កំណើនឆាប់រហ័សនៃឥណទានក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ។

៤- ដូចនេះ ឆ្នាំ២០២០ ដែលជាឆ្នាំទី២ នៃរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ទាមទារឱ្យរាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តកាន់តែមោះមុតបន្ថែមទៀត ក្នុងការដាក់ចេញ និងអនុវត្តនូវវិធានការអន្តរាគមន៍សមស្របឱ្យបានទាន់ពេលវេលា ក្នុងគោលដៅជានាបន្តចលនការទ្រទ្រង់កំណើនសេដ្ឋកិច្ចរឹងមាំ, បង្កើនភាពប្រកួតប្រជែង, ធ្វើពិពិធកម្មសេដ្ឋកិច្ចតាមរយៈការពង្រឹងក្បាលម៉ាស៊ីនកំណើនដែលមានស្រាប់ និងការស្វែងរកចន្ទល់សេដ្ឋកិច្ចថ្មីដែលមានសក្តានុពលខ្ពស់ ព្រមទាំងការរៀបចំខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដូចខាងក្រោម៖

## ២- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២០

### ២.១- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២០

៥- ក្នុងឆ្នាំ២០១៨ កន្លងមកនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនល្អប្រសើររហូតដល់ ៧,៥% លើសពីការរំពឹងទុក ដែលកំណើននេះត្រូវបានគាំទ្រដោយកំណើនខ្ពស់លើសពីការប៉ាន់ស្មាននៃវិស័យកាត់ដេរ, កំណើនរឹងមាំនៃវិស័យសំណង់ និងវិស័យអចលនទ្រព្យ ស្របនឹងកំណើនល្អប្រសើរនៃវិស័យលក់ដុំ-លក់រាយ និងវិស័យដឹកជញ្ជូននិងគមនាគមន៍។ ទន្ទឹមនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំស្ថិតក្នុងរង្វង់ ២,៥% និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៥៣ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យផ.ស.ស. សម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់ ១ ៥៤៨ ដុល្លារអាមេរិក។

៦- ដោយឡែកសម្រាប់ឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តសម្រេចបានកំណើនក្នុងរង្វង់ ៧,១% ហើយ ផ.ស.ស តាមថ្លៃបច្ចុប្បន្នឆ្នាំ២០១៩ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ១០៨ ៥៩០ ប៊ីលានរៀល ហើយកំណើននេះនឹងថមថយមកត្រឹម ៦,៥% ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកផលប៉ះពាល់នៃលទ្ធភាពក្នុងការដក EBA ដែលអាចនឹងដាក់សម្ពាធដល់ការនាំចេញរបស់កម្ពុជា ជាពិសេសលើផលិតផលកាត់ដេរទៅកាន់ទីផ្សារអឺរ៉ុប ហើយ ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ឆ្នាំ២០២០ ត្រូវបានព្យាករថាមានចំនួន ១១៩ ០៣៤ ប៊ីលានរៀល ដែលកំណើននេះត្រូវបានគាំទ្រដោយ៖

• វិស័យកសិកម្មគ្រោងនឹងបន្តសម្រេចបានកំណើនយឺតក្នុងរង្វង់១,៦% ក្នុងឆ្នាំ២០១៩ និង ១,៧ ក្នុងឆ្នាំ២០២០ ដោយសារការថមថយកំណើននៃអនុវិស័យដំណាំ ទោះបីអនុវិស័យនេសាទ និងចិញ្ចឹមសត្វត្រូវបានព្យាករថានឹងនៅបន្តកំណើនខ្ពស់ជាងឆ្នាំកន្លងទៅបន្តិចក្តី។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ១,៧% ក្នុងឆ្នាំទាំងពីរ ដោយសារការថមថយនៃកំណើនផលិតកម្មស្រូវ ដែលបណ្តាលមកពីភាពមានកម្រិតនៃការពង្រីកផ្ទៃដីដាំដុះ, ភាពមិនអំណោយផលនៃកត្តាអាកាសធាតុ (ឥទ្ធិពលបាតុភូតហ្មួតហែង El Niño) និងកំណើនយឺតនៃផលិតភាពដី និងកម្លាំងពលកម្ម។ ដោយឡែកផលិតកម្មដំណាំរួមផ្សំ

និងឧស្សាហកម្មត្រូវបានរំពឹងថានឹងបន្តសន្ទុះកំណើន ដោយសារការកើនឡើងនូវការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម រួមមាន៖ ការវិនិយោគរបស់វិស័យឯកជនលើការកែច្នៃផលិតផលកសិកម្ម ដូចជា ដំឡូងមី, ចេក និងស្វាយ ។ល។ អនុវិស័យនេសាទអាចនឹងសម្រេចបានក្នុងអត្រា ២,២% ក្នុងឆ្នាំ២០១៩ និង ២,៤% ក្នុងឆ្នាំ២០២០ ដែលនឹងជំរុញខ្លាំងដោយអនុវិស័យវារីវប្បកម្ម តាមរយៈការកើនឡើងនូវការវិនិយោគពីវិស័យឯកជន (ទាំងខ្នាតតូច និងមធ្យម) និងការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍។ អនុវិស័យចិញ្ចឹមសត្វក៏ត្រូវបានព្យាករថានឹងមានកំណើនប្រសើរឡើងវិញ ក្នុងរង្វង់ ១,៣% និង ១,៤% ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ដោយសារតែថ្លៃជ្រូករស់ត្រូវបានរំពឹងថានឹងបន្តកើនឡើងក្នុងឆ្នាំ២០១៩ ដែលជំរុញដល់ការបង្កើនការចិញ្ចឹមជ្រូក។ *ជារួម វិស័យកសិកម្មនៅបន្តជួបបញ្ហាប្រឈមជារចនាសម្ព័ន្ធជាច្រើន ដូចជា កំណើនផលិតភាពទាប (ទាំងដី និងពលកម្ម) ភាពមានកម្រិតនៃការវិនិយោគលើវិស័យកែច្នៃកសិផល, ថ្លៃដើមផលិតកម្មខ្ពស់បើប្រៀបធៀបនឹងប្រទេសជិតខាង និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងសមត្ថភាពស្ថាប័ន។*

• វិស័យឧស្សាហកម្មនឹងបន្តរក្សាកំណើនក្នុងអត្រា ១០,៧% ក្នុងឆ្នាំ២០១៩ និងត្រូវបានព្យាករថានឹងមានកំណើនថមថយមកត្រឹម ៨,៩% ក្នុងឆ្នាំ២០២០ ដែលគាំទ្រដោយកំណើនខ្ពស់នៃវិស័យសំណង់ និងវិស័យឧស្សាហកម្មផ្សេងទៀត ខណៈដែលវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនទាប។ វិស័យកាត់ដេរត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរក្នុងអត្រាប្រមាណ ៧,១% ក្នុងឆ្នាំ២០១៩ និងថមថយមកត្រឹម ៣,៥% ក្នុងឆ្នាំ២០២០។ កំណើនយឺតក្នុងឆ្នាំ២០២០ គឺដោយសារការថមថយកំណើនសេដ្ឋកិច្ចសកល ជាពិសេសការរំពឹងទុកផលប៉ះពាល់ដែលបណ្តាលមកពីការដក EBA ដោយសហភាពអឺរ៉ុប ដែលនឹងអាចដាក់សម្ពាធដល់ការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា។ វិស័យសំណង់ត្រូវបានព្យាករថា នឹងបន្តកំណើនរឹងមាំក្នុងអត្រា ១៧,៣% និង ១៦,១% ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងសំណង់អគារលំនៅឋានដែលមានថ្លៃទាប និងមធ្យម ព្រមទាំងសំណង់អគារពាណិជ្ជកម្ម ជំនួសឱ្យកំណើនយឺតនៃសំណង់អគារលំនៅឋានដែលមានថ្លៃខ្ពស់។ វិស័យឧស្សាហកម្មមិនមែនកាត់ដេរ ត្រូវបានព្យាករថានឹងបន្តកំណើនខ្ពស់ក្នុងរង្វង់ ១០,៥% ក្នុងឆ្នាំ២០១៩ និង ១១,៥% ក្នុងឆ្នាំ២០២០ ដោយសារការពង្រីកមូលដ្ឋានផលិតកម្មផលិតផលមិនមែនកាត់ដេរនៃវិនិយោគដែលមានស្រាប់ ទាំងក្នុងនិងក្រៅតំបន់សេដ្ឋកិច្ច, ការរំពឹងទុកនៃនិន្នាការផ្លាស់ប្តូរទីតាំងរបស់រោងចក្រមួយចំនួនពីចិនមកកម្ពុជា, ការបន្តនៃការហូរចូលវិនិយោគពីជប៉ុន និងការបន្តកើនឡើងនៃការផ្គត់ផ្គង់ថាមពលក្នុងស្រុក។ *ទោះជាយ៉ាងណាក៏ដោយ វិស័យឧស្សាហកម្មកម្ពុជានៅមានសក្តានុពលខ្ពស់ក្នុងការរួមចំណែកក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ប៉ុន្តែទាមទារនូវការបន្តជំរុញធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ, ការពង្រឹងការតភ្ជាប់ និងការបណ្តុះបណ្តាលធនធានមនុស្សជាដើម សំដៅពង្រឹងភាពប្រកួតប្រជែង និងពន្លឿនពិពិធកម្មសេដ្ឋកិច្ច។*

• វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ក្នុងរង្វង់ ៦,៧% ក្នុងឆ្នាំ២០១៩ និង ៦,៤% ក្នុងឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃកំណើនល្អប្រសើរនៃវិស័យលក់ដុំ-លក់រាយ, អចលនទ្រព្យ, សណ្ឋាគារ និងភោជនីយដ្ឋាន និងដឹកជញ្ជូននិងគមនាគមន៍។ វិស័យសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរប្រហាក់ប្រហែលឆ្នាំ២០១៨ ក្នុងអត្រា ៥,៦% ទាំងក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ស្របនឹងការរំពឹងទុកនៃការបន្តកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យសណ្ឋាគារ និងមេណីយដ្ឋាន

និងកំណើនភ្ញៀវទេសចរជនជាតិចិន។ *ទោះយ៉ាងនេះក្តី ភាពមានកម្រិតនៃសេវាទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងស្ថាប័ន, អវត្តមាននៃឧស្សាហកម្មនិងសេវាកម្មគាំទ្រ (backward linkages), ការធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍ នៅតែជាប្រការចាំបាច់ និងបន្ទាន់ដែលត្រូវពង្រឹង និងពង្រីក សំដៅធានាចីរភាពកំណើននៃវិស័យនេះ ក្នុងការបន្តតួនាទីជាចន្ទល់មួយសំខាន់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។* វិស័យអចលនទ្រព្យ ត្រូវបានរំពឹងថានឹងបន្តមានកំណើនខ្ពស់ក្នុងរង្វង់ ៨,៨% ក្នុងឆ្នាំ២០១៩ និង ៨,៥% ក្នុងឆ្នាំ២០២០ ដែលស្របគ្នាទៅនឹងនិន្នាការនៃវិស័យសំណង់។ កំណើននៃវិស័យនេះ នឹងត្រូវទ្រទ្រង់ដោយការកើនឡើងនៃសកម្មភាពទិញ-លក់សំណង់អគារដែលមានថ្លៃទាប និងមធ្យមជំនួសឱ្យការថមថយនៃប្រតិបត្តិការទិញ-លក់លំនៅឋានដែលមានថ្លៃខ្ពស់ ដោយសារកំណើនខ្លាំងនៃការផ្គត់ផ្គង់ ធៀបនឹងតម្រូវការ។ វិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានព្យាករថាមានកំណើនល្អប្រសើរក្នុងរង្វង់អត្រា ៧,៩% និង ៧,៧% សម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០ ដោយសារការរំពឹងទុកនូវកំណើនល្អប្រសើរ នៃសកម្មភាពដឹកជញ្ជូនក្នុងវិស័យសំខាន់ៗ និងភាពប្រសើរឡើងនៃវិស័យទូរគមនាគមន៍។ វិស័យលក់ដុំ-លក់រាយ ត្រូវបានព្យាករថានឹងបន្តកំណើនល្អប្រសើរក្នុងអត្រា ៦,៨% ទាំងក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងនៃចំណូលរបស់ប្រជាជន គួបផ្សំនឹងការផ្លាស់ប្តូរឥរិយាបថចំណាយ ទៅរកការចាយខ្ពស់។

• អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតទាបប្រមាណ ២,៨% និង ២,៩% ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ដោយសារការរំពឹងទុកនៃកំណើនយឺតនៃថ្លៃម្ហូបអាហារ និងថ្លៃដឹកជញ្ជូន។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាពក្នុងឆ្នាំ ២០១៩ និងឆ្នាំ២០២០ ពោលគឺស្ថិតក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការជឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

• ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៦% និង ៩,៣% នៃផ.ស.ស. ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០។ ការរួមតូចនៃឱនភាពគណនីចរន្តនេះ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកការបន្តកើនឡើងនៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងការថយចុះនៃឱនភាពសមតុល្យពាណិជ្ជកម្ម ដោយសារការថមថយនៃការនាំចូលវត្ថុធាតុដើមកាត់ដេរ ស្របនឹងកំណើនទាបនៃការនាំចេញផលិតផលកាត់ដេរ។ ទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ១១ ៥០៥ លានដុល្លារអាមេរិក និង ១៣ ០០៧ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ដែលធានាការនាំចូលបាន ៥,៨ ខែ និង ៦,១ ខែ រៀងគ្នា។

៧- ជារួម ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២០ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃការគិតគូរត្រៀមខ្លួនរួចជាស្រេច ដើម្បីឆ្លើយតបនឹងហានិភ័យនៃការដក EBA ដោយសហភាពអឺរ៉ុប និងបានកំណត់ដាក់ចេញនូវវិធានការអន្តរាគមន៍សមស្របនិងទាន់ពេលវេលា ក្នុងគោលដៅបន្តរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចឱ្យបានក្នុងរង្វង់ ៦,៥% ជាមួយអត្រាអតិផរណាទាបដែលអាចគ្រប់គ្រងបានប្រមាណ ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៥០ រៀល ក្នុងមួយដុល្លារអាមេរិក។ ជាមួយគ្នានេះផងដែរ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានរៀបចំឡើងស្របគ្នានឹងបរិការណ៍សេដ្ឋកិច្ចដូចបានរៀបរាប់

ខាងលើ ដោយរាជរដ្ឋាភិបាលនឹងដាក់ចេញនូវគោលនយោបាយវិត្តារកម្មថវិកាក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចឱ្យងើបឡើងវិញនិងបង្កើតការងារជូនប្រជាពលរដ្ឋ តាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីស្រូបយកការប៉ះទង្គិចរយៈពេលខ្លី,ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ, ពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃស្ថាប័នសាធារណៈ។

## ២.២- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០២០

៨- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០២០ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**" មានគោលបំណងដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងចីរភាព ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ និងហានិភ័យ ព្រមទាំងធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- ជំរុញប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ ដែលរួមមាន ការដាក់ឱ្យអនុវត្តសាកល្បងនូវក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២ និងក្របខណ្ឌថវិការយៈពេលមធ្យម ២០២០-២០២២;
- ជំរុញការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣;
- ដាក់ឱ្យអនុវត្តក្របខណ្ឌចំណាយអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជ និងប្រតិបត្តិការក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា;
- បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលក្នុងកម្រិតសមស្រប ដោយផ្អែកទៅលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ក្នុងគោលដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ;
- បន្តអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពសំដៅធានាបាននូវចីរភាពបំណុល;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ តាមរយៈការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន និងវិស័យថាមពល ក៏ដូចជាការតភ្ជាប់វិស័យឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់

ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ;

• បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម។

៩- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០២០ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ២០២០ ដូចខាងក្រោម៖

## ២.២.១- ក្របខណ្ឌចំណូលថវិកាឆ្នាំ២០២០

១០- គម្រោងចំណូលថវិកាឆ្នាំ២០២០ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ២០២០ គ្រោងសម្រេចឱ្យបាន ២២,៥២% នៃផ.ស.ស. គឺមានកំណើន ៣,០១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២៦,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៩) ក្នុងនោះ៖

• ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ២២,៣៦% នៃផ.ស.ស. គឺមានកំណើន ៣,០៣ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២៦,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩។ **ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៩,៧៨% នៃផ.ស.ស.គឺមានកំណើន ១,៤១ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ២៨,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៩,៦៩% នៃផ.ស.ស. គឺមានកំណើន ១,២៧ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២៦,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៨៨% នៃផ.ស.ស. គឺមានកំណើន ០,៣៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២៤,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩។

• **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន ០,១៦% នៃផ.ស.ស. គឺកើនឡើង ០,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩។

• ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៥,០៩% នៃផ.ស.ស. គឺមានកំណើន ០,១៩ ពិន្ទុភាគរយ នៃផ.ស.ស. ឬកើនឡើង ១៣,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,២១% នៃផ.ស.ស.។

១១- ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។

### ក.១- ផ្នែកចំណូលពន្ធដារ

១២- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ រួមមាន៖

- ការបន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមានការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា តាមរយៈ៖
    - រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជី និងរៀបចំយន្តការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័នផ្សេងៗ;
    - បន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដែលបានពីលទ្ធផលនៃការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;
    - បញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ជាមួយវិស័យឯកជន អំពីការផ្តល់សេវាពន្ធដារ;
    - រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមានលក្ខណៈ-នវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកបង់ពន្ធ;
    - ជំរុញការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការចុះបញ្ជី (e-registration), ការដាក់លិខិតប្រកាសពន្ធ (e-filing), និងការបង់ប្រាក់ពន្ធ (e-payment) ឱ្យមានលក្ខណៈស្វ័យ-ប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាតាមនិយាមអន្តរជាតិ;
    - ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្មរួម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ;
    - ដាក់ឱ្យអនុវត្តផែនការជាតិស្តីពីសវនកម្ម (National Audit Plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្មដោយផ្អែកលើកម្រិតហានិភ័យ (risk-based audit);
    - បន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស;
    - ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
    - ដាក់ឱ្យអនុវត្តតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និង
    - ពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ដើម្បីធានាទំនុកចិត្តរបស់អ្នកបង់ពន្ធ។
- បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ៖
    - បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីបង្កើនការប្រមូលចំណូលពន្ធ;
    - បន្តសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងកែសម្រួលចំណុចខ្វះខាតនៃច្បាប់ស្តីពីសារពើពន្ធ;

- ពង្រឹងយន្តការតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា និងការកែប្រែគោលនយោបាយពន្ធដារនៃប្រទេសក្នុងតំបន់ និងសកលលោក;
- ដាក់ឱ្យអនុវត្តការរៀបចំឡើងវិញនូវដំណើរការការងារ និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា;
- បន្តពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់អ្នកគ្រប់គ្រង និងមន្ត្រីជំនាញ តាមរយៈការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស;
- ដាក់ឱ្យអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងចាត់ចែងចំនួនមន្ត្រី និងបង្កើតនីតិវិធីប្រតិបត្តិសម្រាប់ការគ្រប់គ្រង (standard operating procedure) នៅគ្រប់អង្គភាពពន្ធដារ;
- ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីជានាតម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចផ្ទៃក្នុង;
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា និងបន្ថែមមុខងារថ្មីៗ ក្នុងប្រព័ន្ធនៃការគ្រប់គ្រងការចុះបញ្ជីសហគ្រាស, ការធ្វើសវនកម្ម, ការបង្វិលសង VAT, ការចុះបញ្ជីអចលនទ្រព្យ, ការបង់ប្រាក់ពន្ធ, ការតាមដាន និងវិភាគចំណូល, ការតាមដានឯកសារចេញ-ចូល និងការគ្រប់គ្រងធនធានមនុស្ស;
- រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ (១)-Help desk system ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព, (២)-ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA system), (៣)-ការគ្រប់គ្រងដំណើរការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ និង (៤)-ការបញ្ចូលទិន្នន័យលិខិតប្រកាសប្រចាំខែ និងប្រចាំឆ្នាំដោយស្វ័យប្រវត្តិ (automated data capturing system) សម្រាប់អ្នកជាប់ពន្ធ តូច មធ្យម និងធំ និង
- សិក្សា និងបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាព័ត៌មាន (security operation center - SOC)។

**ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ**

១៣- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ រួមមាន៖

• ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលនឹងអាចកើតមានក្នុងឆ្នាំ២០២០ វិធានការគន្លឹះដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ២០២០ ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមាន២ ផ្នែក និងផ្តោតលើគោលដៅជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំ២០២០ រួមមាន៖

• បន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម៖
  - កាត់បន្ថយ និងធ្វើសាមញ្ញកម្មនីតិវិធីគយ ឱ្យកាន់តែខ្លី និងងាយស្រួល តាមរយៈការធ្វើវិមជ្ឈការ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងកិច្ចសហប្រតិបត្តិការគយ;

- ○ បន្តអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងត្រូវពិនិត្យលទ្ធភាពបង្កើនចំនួន Best traders ហើយត្រូវចាប់ផ្តើមរៀបចំអនុវត្តយន្តការ AEO (Authorized Economic Operator) ជាមួយប្រទេសជិតខាង ឬជាមួយប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា;
- ○ កែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ, ប្រព័ន្ធ e-customs, ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
- ○ ជំរុញអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិពេញលេញឱ្យបានឆាប់រហ័ស;
- ○ កែលម្អវិធីសាស្ត្រនៃការកំណត់សូចនាករហានិភ័យដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រងហានិភ័យគយ (customs risk management database system);
- ○ ពិនិត្យ និងវាយតម្លៃឡើងវិញលើ (១)-បញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ (prohibited and restricted goods) និង (២)-ភាពចាំបាច់នៃការប្រើប្រាស់លិខិតអនុញ្ញាតគយសម្រាប់ការនាំចេញ និងការនាំចូល ដើម្បីជួយសម្រួលបន្ទុករដ្ឋបាល ក៏ដូចជារួមចំណែកក្នុងការកាត់បន្ថយបន្ទុកចំណាយ និង
- ○ បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ, ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

• បន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច៖

- ○ បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលពន្ធគយដែលបាត់បង់ពីការអនុវត្ត FTAs, ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និងការកើនឡើងនៃការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
- ○ ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់;
- ○ ចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១). ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករនាំចូល, និង ២). លើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យ ដើម្បីជាមូលដ្ឋានអាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;
- ○ អនុវត្តសវនកម្មគយពេញលេញ (comprehensive custom audit) តាមរយៈការចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែង ជាជាងការត្រួតពិនិត្យតែលើឯកសារ;

- កំណត់ក្រុមហ៊ុនដែលត្រូវធ្វើសវនកម្មដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដើម្បីបង្កើនប្រសិទ្ធភាពសវនកម្ម;
- បញ្ចប់ និងអនុវត្តយុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy) និងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន (ICT strategy);
- ពិនិត្យឡើងវិញ កម្រិតពិន័យបទល្មើសគយ ដើម្បីធានាប្រសិទ្ធភាពការងារបង្ការបទល្មើស;
- កែលម្អ និងពង្រឹងយន្តការគ្រប់គ្រងព័ត៌មានបទល្មើសគយ ដោយបែងចែកឱ្យបានច្បាស់លាស់រវាងចំណូល និងប្រាក់ពិន័យដែលបានពីករណីបទល្មើសតូច និងធំ;
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយ ជាពិសេសការងាររបស់ការិយាល័យនាវាចរគយ;
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋាន ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ និង
- ជំរុញលើកកម្ពស់អនុលោមភាពវិស័យឯកជន ដោយពង្រឹងក្រមសីលធម៌ដើងសារគយ, បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងដល់ពុរជនអំពីតម្លៃ និងកិត្តិយសនៃវប្បធម៌បង់ពន្ធស្អាតស្អំ និងផលវិបាកនៃអំពើគេចវេស និងបន្លំពន្ធ។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៤- វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ រួមមាន៖

• បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;

• បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេលជាមួយយន្តការដែលមានស្រាប់;

• បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការស្ថាប័ន, ការបែងចែកភារកិច្ច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់, ការធ្វើសវនកម្ម និងអធិការកិច្ចលើអង្គភាពប្រមូលចំណូល, និងការដាក់ទោសទណ្ឌ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;

• ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានពេញលេញនៅថ្នាក់ជាតិ និងឈានទៅពង្រីកប្រព័ន្ធនេះនៅថ្នាក់ក្រោមជាតិ;

• រៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយអនុវត្តសាកល្បងជាប្រព័ន្ធក្រៅបណ្តាញ (offline system) សម្រាប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់;

• ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ;

• ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន;

• បន្តពិនិត្យ និងកែសម្រួលកម្រងសេវាសាធារណៈ ដើម្បីពិនិត្យលទ្ធភាពដាក់បញ្ចូលនូវប្រភពចំណូលថ្មីបន្ថែមទៀត ស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជា;

• រៀបចំប្រកាសអន្តរក្រសួង លើការចែករំលែកចំណូលសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល;

• ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចឱ្យអស់សក្តានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;

• បន្តសិក្សា និងរៀបចំជាបណ្តើរៗនូវក្របខណ្ឌគតិយុត្តថ្មីស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ ដែលបានធ្វើសវនកម្មឯករាជ្យ;

• បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការអន្តរ-ក្រសួងដែលមានស្រាប់ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការកើតមានបំណុលថ្មី, ការតឹងទារបំណុល និងការលុបបំណុលរ៉ាំរ៉ៃដែលមិនអាចទារបាន;

• ពន្លឿនការអនុវត្តយន្តការកំណត់ និងបង់កម្រៃសេវា រួមមាន កម្រៃលេខទូរគមនាគមន៍, កម្រៃពីហ្វ្រេកង់ និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ;

• រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីវិស័យប្រៃសណីយ៍;

• ប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;

• បង្កើនសមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូល ដែលមានសក្តានុពលក្នុងវិស័យរ៉ែ និងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផល (equity share) ឱ្យមានប្រសិទ្ធភាព;

• បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសិក្សាកែតម្រូវប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់អាជីវកម្ម និងគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ;

• បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ;

• ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និង ជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;

• ជំរុញការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិត បទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់;

• ពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលឱ្យអស់លទ្ធភាពពីអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ

• តាមរយៈការពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត;

• ធ្វើប្រតិភូកម្មការចេញលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ខ្នាតតូច និងកម្រៃដែលទទួលបានពីលិខិតនេះ ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត;

• ពង្រឹងយន្តការត្រួតពិនិត្យ និងការអនុវត្តក្របខណ្ឌបទប្បញ្ញត្តិដែលមានជាធរមាន ដើម្បីធ្វើការ ផាកពិន័យចំពោះគ្រឹះស្ថានជានារ៉ាប់រង និងសោធន ដែលមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ;

• ដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មអចលនវត្ថុ ក្នុងគោលដៅជំរុញឱ្យ ក្រុមហ៊ុនប្រកបអាជីវកម្មគ្មានអាជ្ញាបណ្ណ មកស្នើសុំអាជ្ញាបណ្ណពីក្រសួងស្របតាមច្បាប់ជាធរមាន;

• ដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងអាជីវកម្មពុះដីឡូត៍លក់។

## ២.២.២- ក្របខណ្ឌចំណាយថវិកាឆ្នាំ២០២០

ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និង អនុវត្តអន្តរាគមន៍ចាំបាច់នានា, គម្រោងចំណាយថវិកាឆ្នាំ២០២០ ត្រូវបានកំណត់ និងវិភាជ ដូចខាងក្រោម៖

• **ចំណាយសរុបថវិការដ្ឋ** នៅឆ្នាំ២០២០ នឹងកំណត់ក្នុងរង្វង់ ២៨,៤០% នៃផ.ស.ស. គឺកើនឡើង ៣,៣៨ ពិន្ទុភាគរយនៃផ.ស.ស. ឬមានកំណើន ២៤,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៩) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៦,៤៨% នៃ ផ.ស.ស. និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៨៣% នៃផ.ស.ស. ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធន ដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៩១% នៃផ.ស.ស.។ **ចំណាយចរន្តថវិការដ្ឋ**ត្រូវកំណត់ក្នុងកម្រិត ១៦,៧៥% នៃផ.ស.ស. គឺកើនឡើង ០,២៦ ពិន្ទុភាគរយនៃផ.ស.ស. ឬមានកំណើន ១១,៣% ធៀបនឹងច្បាប់ថវិកា ឆ្នាំ២០១៩ ដែលក្នុងនោះ៖

- **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៦,៣% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧៥% នៃផ.ស.ស. ដែលត្រូវបានផ្តោតអាទិភាពលើការបង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់ សេវាសាធារណៈ។
- **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥៣,៧% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៩,០% នៃផ.ស.ស. ដោយផ្តោតសំខាន់លើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់ នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាក្របខណ្ឌ គោលនយោបាយជាតិគាំពារសង្គមជាដើម។

ទន្ទឹមនេះ សម្រាប់ឆ្នាំ២០២០ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១១,៦៥% នៃ ផ.ស.ស. គឺមានកំណើន ៣,១២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៤៩,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៩ ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើន សេដ្ឋកិច្ច។ **ចំណាយសរុបថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោង វិភាជទៅតាមវិស័យ ដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ២,២៥% នៃផ.ស.ស. និងមានការកើនឡើង ៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៩៩% នៃផ.ស.ស. និងមានកំណើន ៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៦១% នៃផ.ស.ស. និងមានកំណើន ២៥,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៥៨% នៃផ.ស.ស. និងមានកំណើន ៣៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩។

• **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវកំណត់ត្រឹម ១៥,២១% នៃផ.ស.ស. មានកំណើន ៧,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩ ដែលក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៨,០៤% នៃ ចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៣១% នៃផ.ស.ស. និង**ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រ ស្មើនឹង ៥១,៩៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៩១% នៃផ.ស.ស.។

• **ចំណាយចរន្តថវិការាជធានី-ខេត្ត, មូលនិធិក្រុង ស្រុក ខណ្ឌ និងមូលនិធិឃុំ-សង្កាត់** ត្រូវកំណត់ត្រឹម ០,៩១% នៃផ.ស.ស. កើនឡើង ៣៥,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩ ដែលក្នុងនោះ ថវិកាផ្ទាល់ របស់រាជធានី-ខេត្ត សរុបមានប្រមាណ ១,៥៤% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី-ខេត្ត ស្មើនឹង ០,០៤% នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិក្រុង ស្រុក ខណ្ឌ ស្មើនឹង ០,២០% នៃផ.ស.ស. ឬស្មើនឹង ១,២០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៩, និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០២០ ស្មើនឹង ០,៥១% នៃផ.ស.ស. ឬស្មើនឹង ៣,១០% នៃចំណូលចរន្ត ថវិកាថ្នាក់ជាតិឆ្នាំ២០១៩, ព្រមទាំង ការបង្កើនឧបត្ថម្ភធនបន្ថែមចំនួន ១,០០% នៃចំណូលចរន្តថវិកាថ្នាក់ ជាតិឆ្នាំ២០១៩ ដែលស្មើនឹង ០,១៦% នៃផ.ស.ស. សម្រាប់មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ដែលតាមរយៈ នេះ ថវិកាសម្រាប់អភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់នីមួយៗ ជាមធ្យមនឹងកើនឡើងជាង ២ ដង នៅឆ្នាំ២០២០។

១៦-ក្នុងក្របខណ្ឌនៃគោលដៅទ្រទ្រង់ចលនការនៃការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងបរិការណ៍នៃការកើនឡើង នូវភាពមិនច្បាស់លាស់ និងហានិភ័យពាក់ព័ន្ធ ជាពិសេសលទ្ធភាពនៃការដក EBA ដោយសហភាពអឺរ៉ុប **រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការដាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២០** ដូចខាងក្រោម៖

• គិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗរបស់ រាជរដ្ឋាភិបាល ក្នុងករណីមានវិបត្តិផ្សេងៗ និងប្រធានស័ក្តិ;

• បន្តបង្កើនការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការរៀបចំថវិកាឈរលើមូលដ្ឋានចាំបាច់ជាក់ស្តែង និងចំទិសដៅ ជាពិសេស ការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា;

• កំណត់លក្ខខណ្ឌជ្រើសរើសក្របខណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព ដែលទទួលបានគោលការណ៍ឯកភាពដោយក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសាមី;

• បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅ បង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;

• បន្តគាំទ្រការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ តាមរយៈការបន្ត អនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកាត់បន្ថយ គម្លាតរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី;

• បន្តរក្សាអាទិភាព និងវិចារណកម្មចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធ ដឹកជញ្ជូននិងឡជីស្ទីក, កសិកម្ម, សហគ្រិនភាព និងសេដ្ឋកិច្ចឌីជីថលជាដើម;

• ពង្រឹងការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ;

• ដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីក្របខណ្ឌរួម សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ រួមមាន៖ ១). ការរៀបចំផែនការមេវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ក្រសួង-ស្ថាប័ន, ២). ការកំណត់គោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យគម្រោងដែលតម្រូវឱ្យមានការសិក្សាសមិទ្ធលទ្ធភាព និង ៣). ការធ្វើសមាហរណកម្ម ប្រតិទិននៃការរៀបចំផែនការគម្រោងវិនិយោគទៅនឹងប្រតិទិនរៀបចំថវិកា;

• បង្កើនទំហំ និងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាព ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធ ទូរគមនាគមន៍ ក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែងកម្ពុជា និងបង្កើតការងារជូនប្រជាពលរដ្ឋ ក្នុងនោះ ជំរុញឱ្យបញ្ចប់ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការមេតាមវិស័យសំខាន់ៗនេះ;

• ពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់វិធានការ, បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ លទ្ធកម្មសាធារណៈជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពនៃចំណាយសាធារណៈ;

• បន្តជំរុញការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ តាមរយៈការផ្ទេរសិទ្ធិអំណាចក្នុងការចាត់ចែង ចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង-ស្ថាប័ន និងពីអង្គភាពហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ទៅ អង្គភាពអនុវត្តការងារផ្ទាល់;

• បន្តកាត់បន្ថយនីតិវិធីចំណាយ ជាពិសេសបរិបទចំណាយថ្មីសម្រាប់ការអនុវត្តថវិកាកម្មវិធី តាមរយៈ ការប្តូរពីការត្រួតពិនិត្យមុនចំណាយ ទៅត្រួតពិនិត្យក្រោយចំណាយ និងដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅតាមក្រសួង-ស្ថាប័ន;

• ជំរុញការរៀបចំគោលនយោបាយ និងក្របខណ្ឌវិមជ្ឈការហិរញ្ញវត្ថុរយៈពេលខ្លី និងវែង ដើម្បីបន្តរួមចំណែកក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរាជធានី-ខេត្ត និងក្រុង-ស្រុក ជាពិសេសកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ;

• បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះដែលបានគ្រោង រួមមាន៖

- កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ១,៥ ប៊ីលាន ទៅ ២ ប៊ីលាន អេសដេអ៊ែរ ក្នុងមួយឆ្នាំ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា;
- រក្សាអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផ.ស.ស. (present value of external public debt to GDP) ឱ្យស្ថិតក្រោម ៤០ %;
- បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ៖ ១). ការអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់គ្រប់ដំណាក់កាល, ២). ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និង ៣). ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;
- បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, វិស័យឯកជនក្រោមក្របខណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, និងទីផ្សារមូលបត្រ និង
- បន្តពង្រឹងការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាននិងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលដាយថាហេតុដែលអាចកើតចេញពី៖ ១). ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, ២). វិស័យធនាគារ និងហិរញ្ញវត្ថុ និង ៣). ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២.២.៣-ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ២០២០

១៧- ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ៥,៦១% នៃផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,៨៨% នៃផ.ស.ស. នៅក្នុងឆ្នាំ២០២០។ ប្រការនេះ នឹងផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែង

របស់សេដ្ឋកិច្ចកម្ពុជា និងការបន្តដំឡើងបៀវត្សសមរម្យជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ទន្ទឹមនឹងការបន្តធានារក្សាបាននូវលំហថវិកាក្នុងទំហំមួយសមស្របសម្រាប់ត្រៀមទប់ទល់នឹងវិបត្តិ ក៏ដូចជាហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ។

## ៣- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០២០

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ២០២០

១៨- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ២០១៩),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ២០២០

១៩- **ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ** ត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ និងស៊ីសង្វាក់គ្នាដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ ***សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។***

២០- **គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ** ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា

(ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗ ឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។

លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៨ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ២០១៩ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២១- ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ២០២០-២០២២ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល, **ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ២០២០ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនក្នុងកម្រិតកញ្ចប់ថវិកាដែលបានផ្តល់ជូនជាពិតានចំណាយគោលឆ្នាំ២០២០ និងត្រូវអនុលោមទៅតាម គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍នៃការដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ គោលការណ៍លម្អិតសម្រាប់ការគ្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ២០២០ រួមមាន៖

- ត្រូវគ្រោង**ចំនួនក្របខណ្ឌថ្មី** យ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ និងត្រូវបញ្ជាក់ពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័ន អាចស្នើសុំប្រើប្រាស់ថវិកានោះ ដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមាន**គុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់** និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ជាពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗរបស់ក្រសួង-ស្ថាប័ន,*
- ត្រូវគ្រោង**បៀវត្សមូលដ្ឋាន** ដោយផ្អែកតាមក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០១៩, តាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅក្នុងឆ្នាំ២០១៩ ដោយ**ដំឡើងបៀវត្សមូលដ្ឋានចំនួន ៧% គិតជាតម្លៃសន្ទស្សន៍ក្នុង ១ ឯកតាសន្ទស្សន៍ ស្មើនឹង ២ ៥០០ រៀល** ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ,

- ត្រូវគ្រោងដំឡើង**ប្រាក់បំណាច់មុខងារ**ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយផ្តល់**បន្ថែមជូន ៣០ ០០០ រៀល** សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ក្នុងកម្រិតចាប់ពី ៩៦០ ០០០ រៀល ចុះក្រោម និងផ្តល់**បន្ថែមជូន ២០ ០០០ រៀល** សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៩៦០ ១០០ រៀល ដល់ ១ ១១០ ០០០ រៀល ដោយគិតចាប់ពីខែមេសា ដល់ខែធ្នូ,
- ត្រូវគ្រោង**ចំនួនមន្ត្រីជាប់កិច្ចសន្យា មិនឱ្យលើសពីចំនួន** ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ២០១៩ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោង**ដំឡើងពី ៦៥០ ០០០ រៀល ទៅដល់ ៦៧០ ០០០ រៀល** ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ,
- ត្រូវគ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៣ ចំនួន ៥០ ០០០ រៀល ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ចំនួន ៥០ ០០០ រៀល ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន,
- គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **មិនត្រូវគ្រោងថវិកាសម្រាប់មន្ត្រីមានជំងឺ (អនុគណនី ៦៤០៥១)** ទៀតទេ ព្រោះកញ្ចប់ថវិកានេះត្រូវបានគ្រោងរួមគ្នាដោយឡែករួចហើយសម្រាប់ **បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស.) អនុវត្តការបើកផ្តល់ ស្របតាមព្រះរាជក្រឹត្យលេខ នស/ រកត/ ០២១៧/ ០៧៨ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧, អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, និងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន,
- ចំពោះកញ្ចប់ថវិកាសម្រាប់ការដំឡើងរបបសន្តិសុខសង្គមអប្បបរមាប្រចាំខែ នឹងត្រូវបានគ្រោងដោយឡែកនៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដើម្បីបន្តកាត់បន្ថយគម្លាតប្រាក់សោធននិវត្តន៍រវាងអ្នកចូលនិវត្តចាស់ និងថ្មី ហើយការដំឡើងនេះនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ដោយគិតចាប់ពីខែមេសា ដល់ខែធ្នូ,
- សម្រាប់ឆ្នាំ២០២០ ក៏ដូចជាសម្រាប់ឆ្នាំបន្តបន្ទាប់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវគ្រោងប្រាក់ឧបត្ថម្ភរបបសន្តិសុខសង្គមនៅក្នុងអនុគណនី ៦២០១២ សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងនៅក្នុងអនុគណនី ៦២០១៣ សម្រាប់អតីតយុទ្ធជន។

ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន) ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ ដូចខាងក្រោម៖

- កំណត់*ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់* ។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ការចំណាយសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។**

- *កំណត់ចំណាយមិនប្រចាំ ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍ សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគ ច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ។

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ២០២០ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកានៃពិតានចំណាយគោលនេះ មិនទទួលបានជាស្វ័យប្រវត្តិនោះទេ។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចជាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ មានន័យថា ពិតានចំណាយគោលនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សា នៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន៖** ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ២០២០ មន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃច្បាប់ឆ្នាំ២០១៩ ប៉ុន្តែត្រូវកត់សម្គាល់ថាកញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ

មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ សម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មី ដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណជាតុចូល ដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៨ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០១៩ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណជាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិតសម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ២០១៩ ហើយលែងត្រូវការនៅក្នុងឆ្នាំ២០២០ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៩។ លើសពីនេះ ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថាលែងមានសារៈសំខាន់ ដូចជា **សកម្មភាពចូលរួមតាំងពិពណ៌ពាណិជ្ជកម្ម និងពិពណ៌ទេសចរមួយចំនួនដែលលែងមានភាពចាំបាច់។** ក្នុងន័យនេះ **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី** ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងមានយុត្តការណ៍អំពីភាពចាំបាច់និងបន្ទាន់ មានការពន្យល់ និងផ្តល់អំណះអំណាងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួត-ពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ថវិកានៃពិតានចំណាយគោល ចាំបាច់ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន មន្ទីរ-ជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែមសម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកា ក្នុងក្របខណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យនិងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្តែង។

**- ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព** ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាច ទៅតាមនិងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុង** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។ ទំហំថវិកាដែលនៅសល់ក្នុងក្របខណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុង**ក្រសួង-ស្ថាប័នដដែល ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញនៃក្រសួងមួយ ទៅមន្ទីរជំនាញនៃក្រសួងមួយទៀតបាន** ក្នុងក្របខណ្ឌនៃវិស័យចំណាយតែមួយ។

**គ-ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក២១) និងចំណាយជួសជុល ស្ពាន និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក៦១)** ត្រូវអនុវត្តតាមក្របខណ្ឌនៃការវិភាជដោយឡែក ដោយអនុលោមតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និងក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ក្នុងការកំណត់ទំហំថវិកាសម្រាប់ឆ្នាំ២០២០ ដែលមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ២០១៩ និងរៀបចំបញ្ជីអាទិភាពគម្រោងឆ្នាំ២០២០ ដោយផ្អែកលើគោលការណ៍កំណត់អាទិភាពគម្រោងដែលមាននៅក្នុងសារាចរនេះ។ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នៃសាទ, ក្រសួងមហាផ្ទៃ និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបានការវិភាជថវិកាជាទៀងទាត់, ទំហំថវិកានឹងត្រូវវិភាជជូនស្របតាមអាទិភាពគោលនយោបាយ និងលទ្ធភាពថវិកាប្រចាំឆ្នាំ។ ចំពោះការកំណត់ និងជ្រើសរើសគម្រោងអាទិភាព គឺជាកម្មវត្ថុនៃកិច្ចពិភាក្សាក្រោមយន្តការអន្តរក្រសួងដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើង។ ដោយឡែកសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលជាកម្មវត្ថុទទួលបានថវិកាពីកញ្ចប់ឥណទានថវិកាមិនទាន់បែងចែកត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាវូបនីយកម្មគម្រោងស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលទៅតាមលទ្ធភាពថវិកា។ ទន្ទឹមនេះ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សាត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវតែជាគម្រោងដែលមានក្នុងក្របខណ្ឌគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង-ស្ថាប័នសាមី,
- ជាគម្រោងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច និងសង្គមខ្ពស់,
- ជាគម្រោងដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម,
- ចំពោះគម្រោងធំៗ ត្រូវមានការសិក្សាសមិទ្ធិលទ្ធភាពច្បាស់លាស់។

ជាមួយគ្នានេះ ដើម្បីជាមូលដ្ឋានក្នុងការគ្រោងចំណាយវិនិយោគ (ជំពូក២១) និងចំណាយជួសជុលនិងថែទាំ (ជំពូក៦១) ឆ្នាំ២០២០ ក្រសួង-ស្ថាប័ន ត្រូវផ្អែកលើគោលការណ៍កំណត់អាទិភាពសម្រាប់គម្រោងសាងសង់ ស្ដារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រទៅតាមវិស័យដូចខាងក្រោម៖

- *វិស័យផ្លូវថ្នល់*
  - <u>អាទិភាពទី១</u>: ជួសជុល ស្ដារ និងថែទាំផ្លូវជាតិគ្រប់ប្រភេទ ដើម្បីធានាចីរភាពនៃប្រព័ន្ធគមនាគមន៍ និងចរាចរ។
  - <u>អាទិភាពទី២</u>: ជួសជុល ស្ដារ និងថែទាំផ្លូវខេត្ត និងផ្លូវជនបទសំខាន់ៗ ដែលមានលក្ខណៈជាឆ្អឹងខ្នងនៃប្រព័ន្ធគមនាគមន៍ ដែលបម្រើឱ្យការដឹកជញ្ជូននិងចរាចរនៅកម្រិតមូលដ្ឋានផង និងកម្រិតជាតិផង។
  - <u>អាទិភាពទី៣</u>: គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពីសម្ដេចតេជោនាយករដ្ឋមន្ត្រី។
  - <u>អាទិភាពទី៤</u>: គម្រោងបន្តដែលត្រូវស្ដាបនាដើម្បីបង្កើនឬបង្គ្រប់ប្រសិទ្ធភាពប្រើប្រាស់។
  - <u>អាទិភាពទី៥</u>: គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹង អធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។
- *វិស័យធារាសាស្ត្រ*
  - <u>អាទិភាពទី១</u>: ជួសជុល ស្ដារ និងថែទាំប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ ជាពិសេសប្រព័ន្ធធារាសាស្ត្រ ដែលបានស្ដាបនារួចដោយថវិកាជាតិ ឬថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។
  - <u>អាទិភាពទី២</u>: ស្ដាបនាប្រឡាយមេ និង/ឬប្រឡាយរងបន្ថែម ដើម្បីពង្រីកឱ្យអស់សក្ដានុពល

គម្រោងប្រព័ន្ធធារាសាស្ត្រធំៗដែលត្រូវបានស្ដារឡើងវិញចេញដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា។

- អាទិភាពទី៣: ស្ដារបន្តប្រព័ន្ធធារាសាស្ត្រមិនទាន់អនុវត្តចប់ ដើម្បីឱ្យក្លាយជាប្រព័ន្ធធារាសាស្ត្រមានសក្ដានុពលពេញលេញ។
- អាទិភាពទី៤: គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។

២២- ទន្ទឹមនេះ ចំណាយចរន្ត និងចំណាយវិនិយោគរបស់ក្រសួង-ស្ថាប័នមួយចំនួននៅថ្នាក់ជាតិ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអភិវឌ្ឍនៅមូលដ្ឋាន ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម ចាប់ពីឆ្នាំ២០២០ នឹងត្រូវរក្សាមិនឱ្យមានកំណើន ឬអនុញ្ញាតឱ្យកើនតិចតួច ឬកាត់ចេញមួយចំនួននូវប្រភេទចំណាយថវិកាសម្រាប់អន្តរាគមន៍ដល់ថ្នាក់មូលដ្ឋានផ្ទាល់ ដោយទុកឱ្យ ឃុំ សង្កាត់ ធ្វើខ្លួនឯងវិញ ដូចជា ការជីកស្រះ ការជីកអណ្ដូង ការធ្វើបង្គន់អនាម័យ ការជីកប្រឡាយជើងក្អែបនៅតាមឃុំ ជាដើម ។ល។

២៣- **ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ២០២០ របស់ខ្លួនចំនួនពីរច្បាប់ (មួយច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និងមួយច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកែសម្រួលសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្ដាហ៍ទី៣ ខែវិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

**ដោយឡែក ចំពោះចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក២១) និងចំណាយជួសជុល ស្ពាន និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក៦១) ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាន**

និងកំពុងអនុវត្តជាធរមាន។

២៤- ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៨ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ២០២០ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ២០១៨ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០១៩ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០២០។*

២៥- ទន្ទឹមនេះដែរ ត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៩ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ក្នុងការរៀបចំថវិកាឆ្នាំ២០២០ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្ត មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

២៦- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

### ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២០

២៧- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សា និងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងធ្វើការបូកសរុបចំណូល-ចំណាយ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ដាក់ជូនគណៈរដ្ឋមន្ត្រីនៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៩ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយដាក់ជូនរដ្ឋសភាឱ្យបានមុនសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីស្ថាប័ន**

នីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩។

២៨- ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២០ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ **ការចរចាថវិកាកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និងតាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)** លើមូលដ្ឋាននៃគោលការណ៍ និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីជានាប្រសិទ្ធភាពនៃការវិភាជថវិកាក្នុងកម្រិតនៃពិតានកញ្ចប់ថវិកាឆ្នាំ២០២០ដែលបានកំណត់ និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាមួយ មិនបានបំពេញ និងផ្ដល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្តនោះ ឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៤- សេចក្ដីសន្និដ្ឋាន

២៩- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធី ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង ប្រកបដោយចីរភាពក្នុងរង្វង់ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និងសុខុមាលភាពប្រជាជន។

៣០- ទោះជាយ៉ាងណាក្ដី ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្ដូរប្ដេជ្ញ ជាពិសេសត្រូវតែផ្លាស់ប្ដូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា

ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣១- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ថ្ងៃ ពុធ ១០ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ